វិទ្យាស្ថានសភាកម្ពុជា

PARLIAMENTARY INSTITUTE OF CAMBODIA

### ឯកសារស្រាវជ្រាវសង្ខេប

# ប្រតិបត្តិការប្រព័ន្ធសន្តិសុខសង្គម នៅខេត្តកំពង់ស្ពឺ កោះកុង និងក្រុងព្រះសីហនុ

**អ្នកស្រាវជ្រាវ៖**

លោក សូ សុវណ្ណារិទ្ធ

លោកស្រី គឹម កែវធិតា

លោកស្រី តុប ដារី

ខែកុម្ភៈ ឆ្នាំ២០១៩

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៨ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា


១. សេចក្ដីផ្ដើម ........................................................................................................ 1

២. ទិដ្ឋភាពទូទៅនៃសន្តិសុខសង្គម ........................................................................ 1

៣. ប្រតិបត្តិការ និងការគ្រប់គ្រង ប.ស.ស .................................................................. 4

៤. បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មនិយោជិត ..................................................... 6

៥. បញ្ហាប្រឈមនៃការអនុវត្ត ................................................................................... 8

៦. សេចក្ដីសន្និដ្ឋាន ................................................................................................. 8

## ១. សេចក្ដីផ្ដើម

ឯកសារនេះត្រូវបានរៀបចំសម្រាប់ជាជំនួយស្មារតី ដើម្បីគាំទ្រដល់បេសកកម្មរបស់គណៈកម្មការទី ៨ រដ្ឋសភា ក្នុងការត្រួតពិនិត្យលើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព លើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនៃរបបសន្តិសុខសង្គម។ បេសកកម្មនេះ នឹងធ្វើឡើងនៅខេត្តកំពង់ស្ពឺ កោះកុង និងក្រុងព្រះសីហនុ ចាប់ពីថ្ងៃទី ០៣ ដល់ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៩។ ការរកឃើញសំខាន់ៗនៃឯកសារយោងនេះ បានពីការពិនិត្យឡើងវិញយ៉ាងល្អិតល្អន់លើនីតិវិធី និងប្រតិបត្តិការបច្ចុប្បន្នរបស់របបសន្តិសុខសង្គមពីទិន្នន័យដែលមានស្រាប់ របស់រដ្ឋាភិបាល របាយការណ៍អន្តរជាតិ និងអត្ថបទស្រាវជ្រាវនានា។ ការពិនិត្យឡើងវិញនេះ បង្ហាញដំណើរការ និងគោលដៅបន្ទាប់ដែលប្រសើរជាងមុន សម្រាប់សកម្មភាពឆ្ពោះទៅរកការសម្រេចបាននៃផែនការសកម្មភាព ដើម្បីធានាប្រសិទ្ធភាពនៃសេវាសន្តិសុខសង្គម សម្រាប់កម្មករនិយោជិតដែលងាយរងគ្រោះ រួមទាំងកំណើនប្រកបដោយបរិយាប័ន្ន និងការអភិវឌ្ឍសម្រាប់ប្រជាជនកម្ពុជាទាំងអស់។ ឯកសារនេះ ព្យាយាមផ្ដល់នូវព័ត៌មានតាមបរិបទនៃបទពិសោធន៍ពីប្រតិបត្តិការ នៅក្នុងខេត្តគោលដៅទាំងបី ជាមួយនឹងព័ត៌មានទាក់ទងនឹងប្រតិបត្តិការរបបសន្តិសុខសង្គម។

## ២. និន្នាការទូទៅនៃសន្តិសុខសង្គម

ប្រពន្ធ័សន្តិសុខសង្គម ត្រូវបានបង្កើតឡើងក្នុងបំណងដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពសម្រាប់ប្រជាជនកម្ពុជាទាំងអស់[1]។ បេឡាជាតិរបបសន្តិសុខសង្គមជាតិ(ប.ស.ស) បានបង្កើតឡើងនៅក្នុងឆ្នាំ២០០៧ យោងតាមបទប្បញ្ញត្តិច្បាប់ឆ្នាំ២០០២ ស្តីពីការបង្កើតរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់១៩៩៧ (តារាងទី១)[2]។ ប.ស.ស ត្រូវបានអនុវត្តដោយអនុក្រឹត្យ និងប្រកាសមួយចំនួន ដើម្បីផ្តល់នូវគោលការណ៍ណែនាំនៃប្រព័ន្ធសន្តិសុខសង្គមចាំបាច់សម្រាប់បុគ្គលិកវិស័យឯកជនដែលរួមមាន៖

- ការធានារ៉ាប់រងផ្នែកហានិភ័យការងារ
- ការធានារ៉ាប់រងផ្នែកថែទាំសុខភាព
- ប្រាក់សោធននិវត្តន៍

យោងតាម ប.ស.ស ការអនុវត្តជាចាំបាច់លើការធានារ៉ាប់រងផ្នែកហានិភ័យការងារត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០៨ ដោយអនុលោមតាមច្បាប់ការងារស្តីពីរបបសន្តិសុខសង្គមដែលផ្តល់នូវប្រព័ន្ធការពារហានិភ័យការងារសម្រាប់កម្មករនិយោជិត និងការធានារ៉ាប់រងផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតឯកជនក្នុងឆ្នាំ២០១៦(តារាង១)[3, p. 2]។ មកដល់ពេលបច្ចុប្បន្ននេះ មានតែបុគ្គលិករដ្ឋាភិបាល និងអតីតយុទ្ធ

ជនទេដែលទទួលបានប្រាក់សោធននិវត្តន៍ ដោយផែនការសោធននិវត្តន៍របស់រដ្ឋាភិបាល។ កម្មករនិយោជិតឯកជនណា ដែលមានអាយុ៥៥ឆ្នាំ មានសិទ្ធិទទួលបានប្រាក់សោធនជរាភាពបានប្រសិនបើ៖

១. ពួកគេបានចុះបញ្ជីនៅបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) យ៉ាងតិចណាស់២០ឆ្នាំ និង
២. ពួកគេចូលរួមចំណាយយ៉ាងហោចណាស់៦០ខែ សម្រាប់គម្រោងសន្តិសុខសង្គមនៅក្នុងកំឡុងពេល១០ឆ្នាំ។

កម្មករនិយោជិតដែលមានអាយុ ៥៥ឆ្នាំ ប៉ុន្តែមិនបានបំពេញតាមលក្ខ័ណ្ឌដូចខាងលើគឺមានសិទ្ធិទទួលបានប្រាក់វិភាជន៍ជរាភាពដែលត្រូវបើកឲ្យតែម្តងគត់។ ការចុះឈ្មោះសម្រាប់ប្រាក់សោធននិវត្តន៍នៅ ប.ស.ស គឺនៅតែស្ថិតក្នុងតំណាក់កាលរៀបចំនៅឡើយ ដែលចាំបាច់សម្រាប់ក្រុមហ៊ុនទាំងឡាយណាដែលមានកម្មករនិយោជិតចំនួន ៨នាក់ ឬច្រើនជាងនេះ [4]។។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានលម្អិតស្តីពីគម្រោង មានដូចជាវិភាគទាន និងការទូទាត់សម្រាប់ប្រាក់សោធននិវត្តន៍ គឺនៅមិនទាន់មានបញ្ជាក់នៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ឆ្នាំនេះនៅឡើយទេ[5]។

**តារាងទី១ ៖ បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)**

| | |
|---|---|
| ១៩៥៥ | ប្រព័ន្ធសន្តិសុខសង្គមបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ៥៥ និងលេខ ៣០៦[6] |
| ១៩៧៥-១៩៧៩ | ការបំផ្លេចបំផ្លាញស្ថាប័ន ដោយខ្មែរក្រហម |
| ១៩៩៣ | ការបង្កើតនាយកដ្ឋានសន្តិសុខសង្គមទទួលខុសត្រូវលើការការពារសន្តិសុខសង្គមសម្រាប់កម្មករនិយោជិតស្ថាប័នឯកជន |
| ១៩៩៧ | ច្បាប់ការងារ |
| ២០០២ | ច្បាប់ដំបូងស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលត្រូវបានកំណត់ដោយបទបញ្ញត្តិនៃច្បាប់ការងារ |
| ២០០៧ | ដោយផ្អែកលើច្បាប់ការងារ ប.ស.ស ត្រូវបានបង្កើតឡើងជំនួសអោយនាយកដ្ឋានសន្តិសុខសង្គម |
| ២០០៨ | ការធានារ៉ាប់រងផ្នែកហានិភ័យការងារ ក្នុងបទបញ្ញត្តិនៃច្បាប់ការងារ[7] |
| ២០១៦ | ការធានារ៉ាប់រងផ្នែកថែទាំសុខភាពសង្គមសម្រាប់កម្មករនិយោជិតស្ថាប័នឯកជន |
| ២០១៧ | -ប្រកាសលេខ៤០៤ ស្តីពីការអនុវត្តការថែទាំសុខភាពសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងបទប្បញ្ញត្តិនៃការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន |

| | |
|---|---|
| | ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងក្រសួងសុខាភិបាល នៅថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧។<br>-ប្រកាសលេខ៤៤៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មនិយោជិតក្នុង ប.ស.ស សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៧។ និង<br>-ប្រកាសលេខ៤៤៩ ស្តីពីការកំណត់អត្រាភាគទាណ បែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់ប.ស.ស ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៧។ |
| ២០១៩ | គ្រោងនឹងអនុវត្តកម្មវិធីសោធននិវត្តន៍សម្រាប់កម្មករនិយោជិតឯកជន |

បេឡារបបសន្តិសុខសង្គមនេះត្រូវបានគ្រប់គ្រងសម្រាប់វិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដើម្បីធ្វើឲ្យប្រសើរឡើងនូវរបបសន្តិសុខសង្គម សម្រាប់កម្មករនិយោជិតដែលបានចុះឈ្មោះនៅសហគ្រាសឯកជន ឬជាមួយនឹងការបង្កើតដោយកម្មករនិយោជិតចំនួនប្រាំបីនាក់ ឬក៏ច្រើនជាង។ ប្រព័ន្ធនេះត្រូវបានចាត់ទុកជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ(យ.ជ.គ.ស) [8, pp.3-9]។ ការប្តេជ្ញាចិត្តនេះ គឺទាមឲ្យរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលបានចែងថា« *...ប្រជាពលរដ្ឋទាំងអស់មានកាតព្វកិច្ចទទួលបានសន្តិសុខសង្គម និងផលប្រយោជន៍សង្គមផ្សេងៗទៀត ក៏ដូចជាការបង្កើតបញ្ញត្តិនៅក្នុងវិស័យផ្លូវការ...*»[8, p.13]។

ការធានារ៉ាប់រងផ្នែកសន្តិសុខសង្គមនៅកម្ពុជា មានពីរប្រព័ន្ធ មួយសម្រាប់កម្មករនិយោជិតសារជារណៈ និងមួយទៀតសម្រាប់គ្រប់គ្រងលើកម្មករនិយោជិតឯកជន។ ប្រព័ន្ធទីមួយ ត្រូវបានគ្រប់គ្រងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់មន្ត្រីរាជការ ប៉ូលីសទាហាន និងអតីតយុទ្ធជន តាមរយៈបេឡាជាតិរបបសន្តិសុខសង្គម និងមូលនិធិជាតិសម្រាប់អតីតយុទ្ធជន។ ប្រព័ន្ធទីពីរ គ្រប់គ្រងដោយបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)ស្ថិតនៅក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប្រកាសលេខ៤០៤ ពង្រីកផ្នែកថែទាំសុខភាពតាមរយៈមូលនិធិសមធម៌សុខភាពសម្រាប់កម្មករនិយោជិតក្រៅផ្លូវការ និងផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម សម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន (តារាងទី១) ដែលបានអនុវត្តន៍នៅខែមករា ឆ្នាំ២០១៨។ នៅក្នុងវិស័យក្នុងប្រព័ន្ធ «កម្មករនិយោជិតក្រៅប្រព័ន្ធ» គឺសំដៅដល់អ្នកដែលធ្វើការតិចជាងប្រាំបីម៉ោងក្នុងមួយសប្តាហ៍ និង «កម្មករនិយោជិតធម្មតា»។ «ប្រព័ន្ធមូលនិធិសមធម៌ថែទាំសុខភាព» គឺសំដៅលើយន្តការមូលនិធិសម្រាប់គាំពារសុខភាពសង្គម ដែលបានផ្តល់ដល់ប្រជាជនគោលដៅ ដែលអនុញ្ញាតឲ្យពួកគេបានប្រយោជន៍ពីការ

ថែទាំសុខភាពដោយឥតគិតថ្លៃ នៅមណ្ឌលសុខភាពសារធារណៈដែលផ្តល់ថវិការដោយរដ្ឋាភិបាល។ យោងតាមប្រកាសលេខ៤០៤ និយោជក (រួមទាំងអ្នកម៉ៅការការងារ) ត្រូវតែចុះឈ្មោះកម្មករនិយោជិតរបស់ខ្លួនជាមួយបេឡាជាតិរបបសន្តិសុខសង្គមទោះបីជាពួកគេជាបុគ្គលិកធម្មតាក៏ដោយ។

លើសពីនេះទៅទៀត គម្រោងការពារសន្តិសុខសង្គមមួយចំនួន រួមមាន ធ្នប មូលនិធិសមធម៌សុខភាព គម្រោងប័ណ្ណទូទាត់ ការផ្ទេរជាសាច់ប្រាក់ ប័ណ្ណក្រីក្រសម្រាប់ទទួលបានសេវាថែទាំសុខភាព ត្រូវបានអនុវត្តសាកល្បងដោយដៃគូអភិវឌ្ឍន៍ ហើយកំពុងស្ថិតក្នុងដំណាក់កាលពង្រីក និងសំយោគទៅក្នុងប្រព័ន្ធគាំពារសង្គមសម្រាប់ជនក្រីក្រនៅ និងជនងាយរងគ្រោះនៅកម្ពុជា។ ទោះបីជាគម្រោងទាំងនេះមិនត្រូវបានត្រួតពិនិត្យឡើងវិញក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងរួមរបស់ពួកគេត្រូវបានគេចាត់ទុកថាជាយុទ្ធសាស្ត្រការគាំពារសង្គមរបស់រដ្ឋាភិបាលសម្រាប់ជនដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារកម្ពុជា។

## ៣. ប្រតិបត្តិការ និងការគ្រប់គ្រង ប.ស.ស

ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម(ក.ប.ស.ស)ស្ថិតក្រោមក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង សាខាបេឡាជាតិរបបសន្តិសុខសង្គមនៅថ្នាក់ក្រុង និងខេត្តដែលទទួលខុសត្រូវចម្បងចំពោះរដ្ឋបាល ប.ស.ស។

នៅក្រោមរចនាសម្ព័ន្ធប្រតិបត្តិការនៃ ប.ស.ស (នៅក្នុងឧបសម្ព័ន្ធ ១) ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ បានប្តេជ្ញាចិត្តពង្រីកការគ្រប់គ្រងរបស់ ប.ស.ស ដោយពង្រឹងគម្រោងហានិភ័យការងារ និងអនុវត្តន៍ធានារ៉ាប់រងថែទាំសុខភាព ព្រមទាំងផែនការដើម្បីចាប់ផ្តើមគម្រោងសោធនិវត្តន៍ក្នុងឆ្នាំ២០១៨ ក្នុងគោលបំណងលើកកម្ពស់សុខមាលភាពកម្មករនិយោជិតឯកជន(តារាងទី២)។ ការប្រមូលវិភាគទាន និងការគ្រប់គ្រងធនធានដែលច្បាប់រដ្ឋាភិបាលដើរតួជាអ្នកធានាធនធានចុងក្រោយ គឺជាយុទ្ធសាស្ត្រស្ថិតក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលខុសត្រូវលើហិរញ្ញវត្ថុ។ ក្រសួងទាំងពីរ ជាសមាជិករបស់ ប.ស.ស របស់រដ្ឋាភិបាល ឬក្រុមប្រឹក្សាដែលរួមមានៈ

-អ្នកតំណាងម្នាក់មកពីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ(ជាប្រធាន)
-អ្នកតំណាងម្នាក់មកពីទីស្តីការគណៈរដ្ឋមន្ត្រី (សមាជិក)
-អ្នកតំណាងម្នាក់មកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សមាជិក)
-អ្នកតំណាងម្នាក់មកពីក្រសួងសុខាភិបាល(សមាជិក)
-អ្នកតំណាងបុគ្គលិកពីរនាក់(សមាជិក)

-អ្នកតំណាងកម្មករនិយោជិតពីរនាក់( សមាជិក )

-ប្រធានប្រតិបត្តិ ( សមាជិកដោយស្វ័យប្រវត្ត )

អ្នកតំណាងបុគ្គលិក និងកម្មករនិយោជិត បង្កើតស្ថាប័នត្រីភាគីរវាង រដ្ឋាភិបាល និយោជក និងកម្មករនិយោជិត សម្រាប់៖

-អនុមត្ត័លើកថវិកាប្រចាំឆ្នាំរបស់ ប.ស.ស ជាពិសេសសារៈរបស់គម្រោងនីមួយៗ។

-ត្រួតពិនិត្យ និងអនុម័តអត្រាភាគទានលើគម្រោងនីមួយៗ។

-កាលវិភាគ និងកំណត់ផែនការវិនិយោគរបស់មូលនិធិ

-ពិនិត្យ និងអនុម័តបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលរបស់ស្ថាប័ន។

-កំណត់ដំណើរការនៃការជ្រើសរើស បញ្ចប់ ការដំឡើងឋានៈ ការដាក់ទណ្ឌកម្ម និងការផ្តល់ការលើកទឹកចិត្តដល់បុគ្គលិកតាមសំណើរបស់នាយក។

**តារាងទី២៖ ប្រតិបត្តិការរបស់ ប.ស.ស និងគម្រោងសំខាន់ទាំងបី**

| | **ប្រតិបត្តិការ** | **តម្រូវការ និងអត្ថប្រយោជន៍** |
|---|---|---|
| ប.ស.ស គឺគ្រប់គ្រងដោយ ក្រសួងការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ | អង្គភាពគ្រប់គ្រងត្រីភាគីចំណុះទៅដោយតំណាងមកពីខាង រដ្ឋាភិបាល កម្មករនិយោជិត និងនិយោជកតាំងពីឆ្នាំ ២០០៧ | - ប.ស.ស បានចុះឈ្មោះជាក្រុមហ៊ុន/សហគ្រាស<br>- វិភាគទានសមាជិក<br>- ផ្តល់អត្ថប្រយោជន៍ដល់កម្មករនិយោជិត និងគ្រួសាររបស់ពួកគេ |
| គម្រោងធានារ៉ាប់រងផ្នែកហានិភ័យការងារ ជាគម្រោងធានារ៉ាប់រងគឺជាគម្រោងធានារ៉ាប់រងសង្គមដែលចាំបាច់សម្រាប់ទាំងកម្មករនិយោជិតរដ្ឋាភិបាល និងឯកជន កូនជាង និងកម្មករនិយោជិតបណ្តោះអាសន្ន | - ហិរញ្ញប្បទានដោយភាគទានរបស់ពីនិយោជក និងការឧបត្ថម្ភពីរដ្ឋាភិបាល<br>- មន្ទីរពេទ្យដែលបានចុះឈ្មោះ និងទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គមមានចំនួន១,៣៣៣ មណ្ឌលសុខភាពនៅក្នុងប្រទេសកម្ពុជា | - រាល់សហគ្រាស/ក្រុមហ៊ុនទាំងអស់ដែលមានបុគ្គលិកចំនួន៨នាក់ ឬច្រើនជាងនេះគឺតម្រូវអោយចុះឈ្មោះជាមួយ ប.ស.ស<br>- កម្មករនិយោជិតអាចទទួលបានការថែទាំមិនគិតថ្លៃពីមន្ទីសុខាភិបាលដែលទទួលស្គាល់ដោយប.ស.ស<br>- ០,៨% នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ មុនកាត់ពន្ធ ត្រូវបង់ចូល ប.ស.ស យោងប្រកាសលេខ ៤៤៩ មាត្រា ៤[1]។<br>- កម្មនិយោជិត ទទួលបានប្រាក់ឈ្នួលដែលបាត់បង់ចំនួន ៧០% ពីប.ស.សក្នុងអំឡុងពេលអ |

[1] http://www.eurocham-cambodia.org/uploads/53de2-20171110_prakas-no.-449-on-determine-nssf-contribution-rate-for-occupation-risk-and-healthcare-2017_kh.pdf

| | | |
|---|---|---|
| | ដែលចំនួន ៦២កន្លែងនៅក្នុងខេត្តកំពង់ស្ពឺ ១៥កន្លែងនៅក្នុងខេត្តកោះកុង និង២៨កន្លែងនៅក្នុងខេត្តព្រះសីហនុ | សត្ថភាពធ្វើការបណ្ដោះអាសន្ន ដោយសារតែហានិភ័យការងារ ក្នុងករណីអសមត្ថភាពហេតុ ផលប្រយោជន៍ដែលទទួលបានប្រែប្រួលទៅតាមកម្រិតធ្ងន់ស្រាលនៃអសមត្ថភាព អាយុ និងប្រាក់ឈ្នួល។<br>- នៅពេលមានភាពចាំបាច់ខាងផ្នែកវេជ្ជសាស្ត្រ អ្នកថែទាំកម្មករនិយោជិត គឺមានសិទ្ធិទទួលបានប្រាក់ឈ្នួលពាក់កណ្ដាលនៃប្រាក់ឈ្នួលរបស់ពួកគេ<br>- ក្នុងករណីមរណៈភាពដោយសារហានិភ័យការងារ ប.ស.ស បរិច្ចាកលើការចំណាយលើពិធីបុណ្យសពហើយក៏ផ្ដល់ផលប្រយោជន៍ទៅក្រុមគ្រួសារកម្មករនិយោជិតផងដែរ |
| ការធានារ៉ាប់រងសុខមាលភាពសង្គមស្ថិតនៅក្រោមច្បាប់បានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៅខែមករា ឆ្នាំ ២០១៦ | - ធានារ៉ាប់រងសុខមាលភាពសង្គម បានបានរួមបញ្ចូលភាគទានលើមាតុភាព និងជំងឺដែលការប្រមូលភាគទានលើកទីមួយ នៅខែសីហា ឆ្នាំ២០១៧<br>- សហហិរញ្ញប្បទានស្មើភាពគ្នារវាងកម្មករនិយោជិត និងនិយោជកតាមរយៈការបរិច្ចាក១.៣%នៃប្រាក់ឈ្នួលប្រចាំខែ។ | ធានារ៉ាប់រងសុខមាលភាពសង្គមថ្មី ផ្ដល់នូវកញ្ចប់អត្ថប្រយោជន៍ជាមូលដ្ឋានរួមមានៈ<br>១. ការថែទាំផ្នែកវេជ្ជសាស្ត្រ និងការព្យាបាលនៅក្នុងមន្ទីរពេទ្យមិនលើសពី ១៨០ថ្ងៃ ក្នុងរយៈពេលមួយឆ្នាំ<br>២. សេវាការពារ |

## ៤. បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មនិយោជិត

ប្រតិបត្តិការរាល់ថ្ងៃរបស់បេឡាជាតិសន្តិសុខសង្គម ត្រូវបានគ្រប់គ្រងដោយសារខាបេឡាជាតិសន្តិសុខសង្គមនៅតាមក្រុង និងខេត្តនីមួយៗ។

ប្រតិបត្តិការនៃការធានារ៉ាប់រងផ្នែកហានិភ័យការងារ និងថែទាំសុខភាព ត្រូវបានគាំទ្រដោយ១.៣៣៣ មណ្ឌលសុខភាពនៅទូទាំងប្រទេសកម្ពុជា។ មានមណ្ឌលសុខភាពចំនួន៦២នៅខេត្តកំពង់ស្ពឺ ១៥ មណ្ឌលសុខភាពនៅខេត្តកោះកុង និង២៨ មណ្ឌលសុខភាពនៅខេត្តព្រះសីហនុ ដែលបាន បញ្ជិកា កម្មករនិយោជិតសារធារណៈ និងឯកជន អាចទទួលសេវាដោយឥតគិតថ្លៃ ឬការទទួលបាន ប្រាក់សំណងមកវិញពីសាខារបស់បេឡាជាតិសន្តិ សុខសង្គម នៅក្នុងខេត្តរបស់ពួកគេរៀងៗខ្លួន ឬ នៅកន្លែងធ្វើការបាន។




នៅក្នុងកំឡុងពេលឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៧ ប.ស.ស បានពង្រីកការគ្របគ្រោងគម្រោងហានិភ័យការងារនៅទូទាំងប្រទេស ហើយបានបញ្ជិកា សហគ្រាសចំនួន១០.៨៤៩ សហគ្រាសដែលមានកម្មករនិយោជិតចំនួន ១.៤៣៤.៣១៦ នាក់ (ស្ត្រី ៨៦៨.១៦៨នាក់) ស្មើនឹង ៦០,៤៨% នៃពលករឯកជន (សូមមើលរូបភាពទី១)។ ក្នុងចំណោមសហគ្រាសទាំងនោះ មានប្រហែល ៦០% នៃសហគ្រាសរបស់រដ្ឋ និងរោងចក្រផលិតស្បែកជើងដែលបានបញ្ជិកា។ វាគួឲ្យកត់សម្គាល់ដែរថា មិនមានព័ត៌ជាក់លាក់ណាមួយពីប្រតិបត្តិការ ប.ស.ស នៅក្នុងខេត្តគោលដៅទាំងបីនោះទេ(ខេត្តកំពង់ស្ពឺ កោះកុង និងក្រុងព្រះសីហនុ)ពីឯកសារដែលមានស្រាប់នោះទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប.ស.ស កំឡុងឆ្នាំ២០០៨ ដល់២០១៧ បានបង្ហាញថា មាន១៩៤ សហគ្រាស នៅខេត្តកំពង់ស្ពឺ ៣៥៣ សហគ្រាសនៅក្រុងព្រះសីហនុ និង ៤៤ ក្រុមហ៊ុននៅខេត្តកោះកុង បានបញ្ជិកានៅ ប.ស.ស។ កម្រិតនៃ

**តារាងទី៣៖ ប.ស.ស បានចុះបញ្ជីសហគ្រាស/ការបង្កើតតាមប្រភេទសហគ្រាស រវាងឆ្នាំ២០០៨ ទៅ២០១៧**

| | | |
|---|---|---|
| អង្គការក្រៅរដ្ឋាភិបាល | ១៦២ | ១% |
| ក្រុមហ៊ុនផ្នែកផ្តល់សេវាកម្ម | ២១២ | ២% |
| ភោជនីយដ្ឋាន | ២១៩ | ២% |
| សណ្ឋាគារ | ៣៩៩ | ៤% |
| សហគ្រាសផ្សេងៗ/ ការបង្កើតផ្សេងៗ | ៣.៣៦៥ | ៣១% |
| រោងចក្រកាត់ដេរ រោងចក្រផលិតស្បែកជើង | ៦.៤៩២ | ៦០% |
| ទូទាំងប្រទេស | ១០.៨៤៩ | ១០០% |

ប្រភព៖ ប.ស.ស២០០៨-២០១៧

ការផ្សព្វផ្សាយពីយល់ដឹងរវាងប្រជាជនអំពីនិតិវិធីបញ្ជិកា និងអត្ថប្រយោជន៍ពី ប.ស.ស ត្រូវបានធ្វើឡើងដោយសាខារបស់ ប.ស.ស និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ៥. បញ្ហាប្រឈមនៃការអនុវត្ត

រាជរដ្ឋាភិបាលមានផែនការបញ្ចូលប្រព័ន្ធ ប.ស.ស ទៅក្នុងប្រព័ន្ធជាតិគាំពារសុវត្ថភាពសង្គមដើម្បីទទួលបានប្រសិទ្ធិភាពគ្រប់គ្រង ។ ខណៈពេលដែលផែនការសោធននិវត្តន៍សម្រាប់កម្មករនិយោជិតឯកជនត្រូវត្រៀមនឹងដាក់ឲ្យ អនុវត្តការអនុវត្តនោះ ការធានារ៉ាប់រងផ្នែកហានិភ័យការងារ និងគម្រោងធានារ៉ាប់រងសុខភាពកំពង់តែត្រូវបង្កើល្បឿនដើម្បីគ្របដណ្តប់លើកម្មករទាំងអស់នៅក្នុងវិស័យផ្លូវការនិងក្រៅផ្លូវការ។ ខាងក្រោមនេះគឺជាបញ្ហាប្រឈមដែលត្រូវដោះស្រាយសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព៖

- និយោជិកនិងនិយោជិតជាច្រើននៅមិនទាន់យល់ច្បាស់ពី នីតិវិធីនៃការចុះបញ្ជី និងបង់ថវិកាចូលរួម និងកញ្ចប់អត្ថប្រយោជន៍ដែលពួកគេ នឹងទទួលបានពីកម្មវិធីធានារ៉ាប់រងហានិភ័យការងារ និង សុខភាពឡើយ។
- សមត្ថភាពធនធានមនុស្សនិងស្ថាប័ននៃសាខាប.ស.ស នៅមានកម្រិតនៅឡើយសម្រាប់ប្រតិបត្តិការពេញលេញ និង ប្រសិទ្ធភាពកិច្ចការ តាមដាននិងវាយតម្លៃនៃប្រតិបត្តិការ ប.ស.ស. បច្ចុប្បន្ន។
- គុណភាពនៃសេវាសុខាភិបាលនៃកន្លែងខ្លះនៅមានកម្រិត
- ទិន្នន័យតាមដាននិងវាយតម្លៃលើគម្រោងទាំងអស់មិនទាន់បានពង្រឹងគ្រប់គ្រាន់សម្រាប់ការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រទាន់ដល់ការអនុវត្តពេលវេលា។

## ៦. សេចក្តីសន្និដ្ឋាន

មិនមានព័ត៌មានជាក់លាក់ណាមួយទាក់ទងនឹងប្រតិបត្តិការ ប.ស.ស នៅក្នុងខេត្តគោលដៅទាំងបីនោះទេ (កំពង់ស្ពឺ កោះកុង និងក្រុងព្រះសីហនុ) ពីឯកសារដែលមានស្រាប់សម្រាប់ការសិក្សានេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រោយពីការសិក្សាអង្កេតពីប្រព័ន្ធប្រតិប្រត្តិការទូទៅរបស់ ប.ស.ស បានបង្ហាញថា រដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រីកការធានារ៉ាប់រងថៃទាំសុខភាព ការចាប់ផ្តើមគម្រោង

សោធននិវត្តន៍សម្រាប់កម្មករនិយោជិតវិស័យឯកជន និងពង្រីកគម្រោង ប.ស.ស ដល់កម្មករនិយោជិតក្រៅប្រព័ន្ធផងដែរ។

កង្វះខាតធនធានមនុស្ស សមត្ថភាពតាមដាននិងវាយតម្លៃដែលនៅមានកម្រិត វិធីសាស្រ្តកាន់តែមានប្រសិទ្ធភាពក្នុងការបង្កើនការយល់ដឹងអំពីការចុះឈ្មោះបញ្ជីរ និងការចូលរួមវិភាគទាន និងអត្ថប្រយោជន៍របស់ ប.ស.ស ក្នុងចំណោមនិយោជកនិងនិយោជិកទាំងក្នុងប្រព័ន្ធសហគ្រិនផ្លូវការនិងមិនផ្លូវកាចាំបាច់ត្រូវដោះស្រាយបន្ត។ ថ្វីបើមានការប្តេជ្ញាយ៉ាងមុតមាំរបស់រដ្ឋាភិបាលក្នុងការបង្កើតប្រព័ន្ធគាំពារសង្គមមួយសម្រាប់បង្កើនគម្រោងធានារ៉ាប់រងសុខុមាលភាពសង្គមក្តី តែវានៅតែជាមធ្យោបាយដ៏វែងឆ្ងាយដើម្បីបន្តដំណើរទៅមុខទៀត។

## ឯកសារយោង


1. Ministry of Labour and Vocational Training, Cambodia. (2011). *The Overview of Occupational Safety and Health in Cambodia.* Phnom Penh: Ministry of Labour and Vocational Training.
2. Ministry of Labour and Vocational Training, Cambodia. (2016,p.2). Prakas on Determination of Phases and Date of Implementation Of Social Security Scheme on Health Care
3. Minstry of Labour and Vocational Training. (2018). *National Social Security Fund: Report on Ten-Year Acheivements 2008-2017 and Action Plan 2018.* Phnom Penh: Minstry of Labour and Vocational Training.
4. National Social Security Fund. (n.d.). *Social Proteciton Strategy for Persons Defined by Provisons of the Labour Law Year: 2014-2018.* Retrieved from http://www.nssf.gov.kh/default/wp-content/uploads/2016/10/2.-Social-protection-strategy-%E2%80%8B2014-2018-edited.pdf
5. International Labour Organisation. (2017). Social Protection Country Brief-Cambodia available at http://tinyurl.com/y4j3n5o

## ឧបសម្ព័ន្ធ ១៖ រចនាសម្ព័ន្ធរដ្ឋបាលរបស់បេឡាជាតិរបបសន្តិសុខសង្គម( ប.ស.ស )

